**ឧបសម្ព័ន្ធ ក**

**លក្ខខណ្ឌយោង**

តួនាទីៈ **អ្នកបើកបរ**

ទីកន្លែងបម្រើការងារៈ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**សាវតា**

1. នៅក្នុងខែធ្នូ ឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជា (RGC) បានអនុម័តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ដែលជាកម្មវិធីកំណែទម្រង់រយៈពេលវែងដោយផ្អែកលើវិធីសាស្រ្ត ដំណាក់កាលដែលដោះស្រាយបញ្ហាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ ចាប់តាំងពីពេលចាប់ផ្តើមរបស់ខ្លួន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានផ្តល់លទ្ធភាពឱ្យកម្ពុជា សម្រេចបាននូវការរីកចម្រើនយ៉ាងសំខាន់ក្នុងការធ្វើការកែទម្រង់គោលនយោបាយចំណាយសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ។
2. ដំណាក់កាលទីមួយ (២០០៤-២០០៨)÷ គោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រូវបានពង្រឹងទាំងប្រមូលចំណូល, គ្រប់គ្រងថវិកា និងការគ្រប់គ្រងបំណុលសាធារណៈ ដែលឆ្លុះបញ្ចាំងអំពីភាពប្រសើរឡើងនៃវិន័យថវិកា ។
3. បើទោះបីជាមានការយឺតជាងការរំពឹងទុកសម្រាប់ការចាប់ផ្តើមអនុវត្តកម្មវិធីក្នុងដំណាក់កាលទីពីរ (ដែលបានចាប់ផ្តើមក្នុងឆ្នាំ២០០៩) កិច្ចខិតខំប្រឹងប្រែងត្រូវបានបង្កើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលពីរឆ្នាំដើម្បី បង្កើនគណនេយ្យភាពហិរញ្ញវត្ថុស្ថិតនៅក្រោមការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃគម្រោងគណនេយ្យភាព (PFMAP)។ ភាគច្រើននៃ គោលការណ៍អនុត្តការងារផ្អែកទៅលើកាតាលីករពាក់ព័ន្ធគ្នាចំនួនប្រាំដែល ផ្តោតលើការអនុវត្ត FMIS ដែលមានចែងនៅក្នុងយុទ្ធសាស្រ្តអាទិភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF) នឹងបានគាំទ្រដោយក្រុមការងារទាំងបីៈ ក្រុមគណនេយ្យភាព ក្រុមអនុត្តថវិកា និងក្រុមស្តង់ដាគណនេយ្យ។
4. កម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈគឺជា និងនៅតែជាអភិក្រមគ្រប់ដណ្តប់កិច្ចការកែទម្រង់។ បន្ថែមពីលើការគាំទ្រពីពហុម្ចាស់ជំនួយ (MDTF) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានទទួលការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដោយផ្ទាល់មួយចំនួនរួមទាំងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA), អង្គការយូនីសេហ្វ, រតនាគារសហរដ្ឋអាមេរិក និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ។
5. បើទោះបីជាមានការរីកចម្រើន និងការកើនឡើងបែបនេះក៏ដោយ ក៏នៅតែមិនគ្រប់គ្រាន់ដើម្បីឈានដល់គោលដៅ ប្រសិទ្ធភាព និងតម្លាភាព នៃកំណែទម្រង់ប្រទេសឲ្យស្របទៅនឹងការអភិវឌ្ឍនៅក្នុងតំបន់។ ដូច្នេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ត្រូវបានបង្កើតឡើងនៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ដើម្បីបន្តអនុវត្តឲ្យបានជោគជ័យនៃគម្រោងក្នុងដំណើរការការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង

គណនេយ្យភាព (PFMAP) ក្រោមហិរញ្ញប្បទានដោយ IDA ក្រោយពីបានបញ្ចប់កញ្ចប់ថវិកាពីពហុម្ចាស់ជំនួយ (MDTF) និងផ្តោតលើការធ្វើឱ្យប្រសើរឡើងគណនេយ្យភាពហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធិភាព (ដំណាក់កាលទី២ នៃកម្មវិធីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ) ។

6. គោលបំណងនៃការអភិវឌ្ឍគម្រោង គឺដើម្បីផ្តើនការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយពង្រឹង : (ក) ការកៀរគរចំណូលនិង (ខ) ដំណើរការអនុវត្តថវិកាតាមរយៈការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ (FMIS) ផងដែរ។ ការរីកចម្រើនដែលឆ្លើយតបទៅនឹងគោលបំណងដ៏សំខាន់ខាងលើនេះ នឹងត្រូវបានវាស់ដោយមានការចូលរួមចំណែកអនុវត្តកម្មវិធីគន្លឹះ និងគោលដៅដែលកំណត់ចេញទៅនៅក្នុងដំណាក់កាលទីពីរនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការបន្តជំនួយរបស់ធនាគារពិភពលោក និងដៃគូរអភិវឌ្ឍន៍ក្រោមការសម្របសម្រួលពីរាជរដ្ឋាភិបាល ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់របស់ខ្លួនជាច្រើនឆ្នាំកន្លងមក។

7. គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) បានបង្កើតអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ដើម្បីជួយសម្រសម្រួលការងារប្រចាំថ្ងៃក្នុងការអនុវត្តគម្រោង រួមទាំងការធ្វើផែនការគម្រោងពិនិត្យ និងធ្វើរបាយការណ៍ អនុវត្តកិច្ចការងារលទ្ធកម្ម ទូទាត់ចំណាយ និងការគ្រប់គ្រងហិរញ្ញវត្ថុ។ តួនាទីនិងមុខងាររបស់ អ.គ.ហ. មានដូចខាងក្រោម:
   (i) គាំទ្រ និងជួយ គ.ហ.ស. ក្នុងកិច្ចការរដ្ឋបាលនិង Logistic ទាំងអស់។
   (ii) ដើរតួនាទីការសម្របសម្រួលជូន គ.ហ.ស. ក្នុងករណីចាំបាច់ ដូចជារៀបចំឯកសារកិច្ចប្រជុំ សិក្ខាសាលា/ /សិក្ខាសាលា ។ល។
   (iii) សម្របសម្រួលនិងជួយអគ្គនាយកដ្ឋាន/នាយកដ្ឋាន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅពេលដែលមានតម្រូវការដូចជា ការបង្កើត ការអនុវត្ត និងការត្រួតពិនិត្យកម្មវិធីកែទម្រង់នេះ។
   (iv) គាំទ្រផ្តល់ជំនួយបច្ចេកទេសដល់អគ្គនាយកដ្ឋាន/នាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
   (v) ទំនាក់ទំនងជាមួយ DPs ឬក៏មន្ត្រីសម្របសម្រួលរបស់អគ្គនាយកដ្ឋាន ឬទំនាក់ទំនងតាមបណ្តាញ (ឧ. ទំនាក់ទំនងជាមួយលេខាធិការនៃអគ្គនាយកដ្ឋានប្រសិនបើជាមន្ត្រីតែមួយដែលត្រូវធ្វើការទំនាក់ទំនង)
   (vi) ទំនាក់ទំនងជាមួយភ្នាក់ងាររដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត
   (vii) របាយការណ៍ស្តីពីការត្រួតពិនិត្យស្តីពីវឌ្ឍនភាពនៃកម្មវិធីកំណែទម្រង់(សូចនាករនិងការសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការធ្វើការត្រួតពិនិត្យ) ដូចជាការធ្វើ បច្ចុប្បន្នភាពឲ្យបានទៀងទាត់ស្តីពីការផ្តល់ជំនួយការបច្ចេកទេស PFM
   (viii) ផ្តល់យោបល់ជូន គ.ហ.ស. លើសកម្មភាពបង្ការពេលដែលផែនការត្រូវបានអនុវត្តខុសគោលដៅ ក៏ដូចអនុត្តការងារផ្សេងដែលបានស្នើដោយ គ.ហ.ស. ។

អ.គ.ហ. ដឹកនាំដោយអគ្គលេខាធិការ០១រូប និងមានការគាំទ្រផ្នែកបច្ចេកទេសពីអគ្គលេខាធិការរង ប្រធានផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ និងត្រួតពិនិត្យ និងវាយតម្លៃ មន្ត្រីជំនាញជាន់ខ្ពស់ មន្ត្រីជំនាញ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុគណនេយ្យករជាន់ខ្ពស់ គណនេយ្យ មន្ត្រីរដ្ឋបាល និងមន្ត្រីព័ត៌មានវិទ្យា ។

**<u>ភារកិច្ចនិងទំនួលខុសត្រូវ</u>**

ក្រោមការត្រួតពិនិត្យរបស់ឯកឧត្តមអគ្គលេខាធិការ អ្នកបើកបរ នឹងបំពេញភារកិច្ចដូចខាងក្រោម÷

១. បើកបររថយន្តជូនថ្នាក់ដឹកនាំ អ.គ.ហ. ដោយគោរពច្បាប់ចរាចរណ៍ខ្ជាប់ខ្ជួន និងធានាសុវត្ថិភាព ដល់ថ្នាក់ដឹកនាំ

២. ត្រួតពិនិត្យនិងសម្អាតយានយន្តជាប្រចាំមុនពេលបើកបរ

៣. បំពេញបេសកកម្ម តាមការចាត់តាំងរបស់ថ្នាក់ដឹកនាំ

៣. អនុវត្តការថែទាំជាប្រចាំ និងការជួសជុលតិចតួចដល់យានយន្ត

៤. ថែរក្សានិងកត់ត្រាកំណត់ត្រាយានយន្ត (Logsheet) និងសេវាកម្មថែទាំយានយន្ត

៥. រាយការណ៍ទៅអ្នកគ្រប់គ្រងផ្ទាល់អំពីបញ្ហាណាមួយទាក់ទងនឹងយានយន្តឱ្យបានឆាប់បំផុត

៦. ការងារផ្សេងទៀតដែលតម្រូវដោយអ្នកគ្រប់គ្រងផ្ទាល់ ។

**<u>តម្រូវការរបាយការណ៍</u>**

អ្នកបើកបរនឹងរាយការណ៍ដោយផ្ទាល់ទៅមន្ត្រីរដ្ឋបាលជាន់ខ្ពស់ នៃ **អ.គ.ហ.**។

**<u>រយៈពេលបំពេញការងារ និងពេលវេលាបំពេញការងារ</u>**

អ្នករត់ឯកសារ/អ្នកបើកបរ ត្រូវបំពេញការងាររយៈពេល០៨ម៉ោងក្នុង០១ថ្ងៃ ចាប់ពីម៉ោង០៧:៣០នាទីព្រឹក រហូតដល់ម៉ោង ៥:៣០ល្ងាច។ ទីតាំងបំពេញការងារនៅអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**<u>លក្ខណៈសម្បត្តិនិងបទពិសោធន៍</u>**

១.មានអាយុចាប់ពី ២០ ដល់ ៤៥ ឆ្នាំ

២. មានសុខភាព និងកាយសម្បទាល្អ

៣. មានបទពិសោធន៍បើកបរយ៉ាងតិច ២ ឆ្នាំ

៤. ត្រូវចេះបត់បែននិងមានឆន្ទៈធ្វើការថែមម៉ោង

៥. មានចំណេះដឹងផ្នែកភាសាអង់គ្លេសតិចតួច

៦. ត្រូវមានបណ្ណបើកបររថយន្តដែលមានសុពលភាពនៅកម្ពុជា

៧. មានអាទិភាពសម្រាប់អ្នកដែលមិនជក់បារី។